**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបើកឆ្នាំសិក្សានៅទេវវិទ្យាល័យ**
**ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨**
*លះបង់ចោល ដើម្បីទទួលជីវិតអស់កល្បជានិច្ច*

អត្ថបទទី១៖ ២ធម ៩,១០-១៧គ
ដំណឹងល្អ៖ លក ១០,១-៩

បងប្អូនជាទីស្រឡាញ់!

សំណួរដែលយើងបានស្តាប់នៅក្នុងគម្ពីរ គឺសំណួរដែលយើងទាំងអស់ចង់សួរទៅព្រះយេស៊ូ **តើខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីទទួលជីវិតអស់កល្បជានិច្ចទុកជាមរតក?** មនុស្សយើងថ្ងៃណាមួយនៅលើផែនដីនេះយើងអស់ផ្លូវទៅ ថ្ងៃណាមួយនៅលើផែនដីនេះដំណើររបស់យើងចប់ហើយ។ ជាពិសេសយើងជាលោកឪពុក និងនិស្សិតទេវកំពុងត្រៀមខ្លួន ដើម្បីធ្វើជាបូជាចារ្យ សំណួរសម្រាប់យើងផ្ទាល់ និងជាសំណួរមួយដែលបងប្អូនជាគ្រីស្តបរិស័ទ និងបងប្អូនកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់មកសួរដល់យើង។ លោកឪពុកអើយ! តើខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីទទួលជីវិតអស់កល្បជានិច្ច? មុនយើងឆ្លើយតម ឲ្យយើងគិតអំពីយើងផ្ទាល់ខ្លួន ៖

**ចំណុចទី១ ឲ្យព្រះយេស៊ូទតមើលយើង** នៅក្នុងគម្ពីរលោកលូកា "**ព្រះយេស៊ូទតមើលគាត់ដោយមានព្រះហឫទ័យស្រឡាញ់គាត់**"។ មុនព្រះយេស៊ូឆ្លើយ មុនព្រះយេស៊ូមានទស្សនៈមួយ មុនព្រះយេស៊ូមានព្រះបន្ទូល មុនព្រះយេស៊ូធ្វើអ្វីៗទាំងអស់ ព្រះយេស៊ូឈប់សិន និងព្រះយេស៊ូទតមើលគាត់យ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់គាត់ ដើម្បីយល់ពីសេចក្តីត្រូវការរបស់គាត់ខាងក្នុង និងលើសពីនេះទៀតដោយមានព្រះហឫទ័យស្រឡាញ់។ ព្រះយេស៊ូ មិនចាប់ផ្តើមដោយកាត់ក្តី ព្រះយេស៊ូមិនចាប់ផ្តើមដោយវិនិច្ឆ័យ បុរេវិនិច្ឆ័យ ប៉ុន្តែព្រះយេស៊ូទតមើលគាត់ដើម្បីមើលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់គាត់ មើលគាត់ដោយព្រះហឫទ័យស្រឡាញ់ ។ នេះ ជាទំនាក់ទំនងដែលយើងត្រូវតែបង្កើតមុនគេបង្អស់ នៅពេលយើងបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗតាមរយៈព្រះយេស៊ូ។ មើលព្រះយេស៊ូហើយមើលទៀត ដើម្បីយល់អំពីរបៀបព្រះយេស៊ូ និងធ្វើតាម ព្រះយេស៊ូទតមើលគាត់ដោយមានព្រះហឫទ័យស្រឡាញ់។

**ចំណុចទី២ ឲ្យយើងលះបង់ចោលអ្វីៗទាំងអស់** ដើរតាមព្រះយេស៊ូមិនស្រួលទេ បុរស់នោះប្រហែលគាត់ឆ្ងល់ ព្រោះគាត់ខិតខំធ្វើតាមធម្មវិន័យខ្លាំងណាស់គ្រប់ទាំងអស់។ ចម្លើយរបស់ព្រះយេស៊ូ គឺ"**នៅខ្វះកិច្ចការតែមួយទៀត ដែលអ្នកមិនទាន់ធ្វើគឺត្រូវទៅលក់អ្វីដែលអ្នកមាន រួចចែកឲ្យជនក្រីក្រ ធ្វើដូច្នេះទើបអ្នកមានសម្បត្តិសួគ៌ បន្ទាប់មកសុំអញ្ជើញមកតាមខ្ញុំ**" ដើមតាមព្រះយេស៊ូ គឺមានន័យថាលះបង់ចោលអ្វីៗទាំងអស់។ ថ្ងៃនេះ សម្រាប់ ប៊ុនលី និងសំណាង និងសម្រាប់

និស្សិតទេវវិទ្យាល័យផ្សេងទៀត។ យើងត្រូវការគិតនេះ យើងដើមព្រះយេស៊ូគឺយើងលះបង់ចោលអ្វីៗទាំងអស់ យើងលះបង់ចោលឪពុកម្តាយ បងប្រុស បងស្រី ផ្ទះ ដី អ្វីៗទាំងអស់ ដើម្បីយកព្រះយេស៊ូជាអទិភាព។ បន្តិចទៀតពេលយើងនឹងឆ្លើយ "**ខ្ញុំចង់ បាទខ្ញុំសុខចិត្ត**" នៅពេលយើងឆ្លើយនេះ យើងចាប់ផ្តើមចូលនៅក្នុងរបៀបពិសេស នៅក្នុងផ្លូវដែលព្រះយេស៊ូបានរៀបចំឲ្យយើង។ ការត្រាស់ហៅ ដែលយើងបានស្តាប់ យើងបានទទួល ថ្ងៃនេះព្រះសហគមន៍ទទួលស្គាល់ពិតមែន ប៊ុនលី និង សំណាង ត្រៀមខ្លួនដើម្បីអនាគតទៅជាលោកបូជាចារ្យ ទៅជាមិត្តសម្លាញ់ពិសេសរបស់ព្រះយេស៊ូ ដែលត្រូវតែអនុវត្តនូវក្នុងការលះបង់ចោល។ ដើរតាមព្រះយេស៊ូមានន័យថាយើងលះបង់ចោលច្រើន លះបង់ចោលដើម្បីទទួលច្រើន ។ ដោយសារលះបង់ចោលហើយតាមរបៀបលោកីយ៍ យើងទទួលយ៉ាងច្រើនដោយសារព្រះយេស៊ូបានសន្យាថា យើងនឹងទទួលបងប្អូនថ្មីៗ បងប្រុសបងស្រីយ៉ាងច្រើនទៀត និងយើងមានជីវិតអស់កល្បជានិច្ចថែមទៀត។ លះបង់ដើម្បីទទួលក្នុងរបៀបថ្មី។

ថ្ងៃនេះដែលព្រះសហគមន៍ដែលមកច្រើន យើងយល់ហើយព្រះសហគមន៍នេះទៅជាក្រុមគ្រួសារដ៏ទូលំទូលាយថ្មី ដែលយើងនឹងស្រឡាញ់ ដែលយើងបម្រើ ដែលស្រឡាញ់យើង និងដែលលើកទឹកចិត្តយើងទៅវិញទៅមក ។ ជាព្រះសហគមន៍នេះ ដែលគាំទ្រយើង ដែលធ្វើដំណើរជាមួយយើង ដែលអធិដ្ឋានសម្រាប់យើង ដែលស្រឡាញ់យើង ដែលលើកទឹកចិត្តយើង។ សម្រាប់យើងជាបូជាចារ្យតាមភូមិភាគ ឥតមានគ្រួសារបព្វជិត បព្វជិតា ដែលលើកទឹកចិត្តយ៉ាងខ្លាំង យើងមានបូជាចារ្យគ្នាយើង និងយើងមានគ្រីស្តបរិស័ទជាពិសេស។ នៅគ្រប់ទំនាក់ទំនងដែលយើងបង្កើតជាមួយក្រុមគ្រីស្តបរិស័ទ ទៅជាក្រុមគ្រួសាររបស់យើង ដែលធ្វើដំណើរជាមួយយើង ដែលលើកទឹកចិត្តយើង ដែលណែនាំឲ្យយើងទៅមុខនៅក្នុងជីវិតរបស់យើងដែលជាសាវ័កនិងគ្រីស្តទូតរបស់ព្រះយេស៊ូ ដើម្បីបន្តលះបង់ចោល ប៉ុន្តែលះបង់ដើម្បីទទួលមរតកយ៉ាងពិសេស។

**ចំណុចទី៣** ផ្លូវដើម្បីដើរតាមព្រះយេស៊ូចង្អៀតណាស់ ប៉ុន្តែយើងមានសមត្ថភាពដោយសារ "**ការនេះមនុស្សធ្វើពុំកើតទេ តែព្រះជាម្ចាស់ធ្វើកើត ដ្បិតព្រះអង្គធ្វើគ្រប់ការទាំងអស់បាន**" នេះជាសំខាន់ណាស់។ ដោយសារយើងដឹងថា យើងទីពឹងលើព្រះយេស៊ូ លើព្រះជាម្ចាស់ទាំងស្រុង។ កម្លាំងរបស់យើង មិនមែននៅក្នុងតែសមត្ថភាពរបស់យើងផ្ទាល់ សកម្មភាពដែលយើងធ្វើរាល់ថ្ងៃ ប៉ុន្តែរបស់យើងដែលយើងរកឃើញនៅក្នុងទំនាក់ទំនងដែលយើងបង្កើតជាមួយព្រះជាម្ចាស់។ ដោយដឹងថា "**ឱព្រះអង្គអើយ! សូមជួយខ្ញុំ**" សូមណែនាំខ្ញុំឲ្យខ្ញុំទៅមុខ។ កុំភ្លេច ព្រះនាងម៉ារីបានឆ្លើយ "**ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមឲ្យសម្រេចតាមព្រះហឫទ័យរបស់ព្រះជា**

**ម្ចាស់ចុះ**”។ ព្រះនាងម៉ារីបានទទួលកម្លាំងពីព្រះជាម្ចាស់ នៅក្នុងចម្លើយរបស់គាត់ ខ្ញុំជឿថា បន្តិចទៀតនៅពេលឆ្លើយថា “**ខ្ញុំស្ម័គ្រចិត្ត ខ្ញុំសុខចិត្ត ដើរជានិស្សិតទេវវិទ្យាល័យ នៅក្នុងព្រះសហគមន៍ ដើម្បីបម្រើព្រះសហគមន៍ និងបម្រើព្រះជាម្ចាស់**” យើងរកឃើញកម្លាំងនៅក្នុងចម្លើយរបស់យើង ដោយដឹងថាព្រះជាម្ចាស់គង់នៅ។

អរគុណបងប្អូនដែលបានចូលរួម អរគុណលោកឪពុកដែលអធិដ្ឋានពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីឲ្យព្រះសហគមន៍របស់យើងរកឃើញអ្នកបម្រើថែមទៀត។ សូមបងប្អូនបន្តអធិដ្ឋានគាំទ្រ ដើម្បីព្រះសហគមន៍របស់យើង អាចមានយុវជនមួយចំនួនដើម្បីបម្រើព្រះសហគមន៍ ដោយដឹងថានៅថ្ងៃនេះជាក់ស្ដែង យើងមកពីគ្រួសារមួយ ដែលបម្រើ ស្រឡាញ់ព្រះជាម្ចាស់យ៉ាងខ្លាំង គ្រួសារនេះបានបង្កើតកូនមួយ និងឲ្យកូននេះទៅបម្រើព្រះសហគមន៍កម្ពុជា។ យើងអធិដ្ឋាននៅក្នុងឆ្នាំគ្រួសារ ដើម្បីឲ្យគ្រួសារនីមួយៗអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ ដោយដឹងថាអ្វីៗទាំងអស់ដែលយើងធ្វើ យើងអាចទទួលរង្វាន់យ៉ាងពិសេស ការលះបង់ចោលរបស់យើង ដើម្បីទទួលជីវិតអស់កល្បជានិច្ច។ អាម៉ែន៕